

# ថាមពលនៃពេលវេលា

Let's Read

The Asia Foundation



តិកតុក! តិកតុក

ហេនរី គេងប្រែខ្លួនចុះឡើងៗជាច្រើនដង។ សំឡេងដើររបស់ទ្រនិចនាឡិកាធ្វើឲ្យគេមួម៉ៅ។ គេងគេងមិនលក់ទេ ដោយសារសំឡេងនោះរាំខាន។



ទ្រនិចវិនាទីនេះហើយ ដែលធ្វើឲ្យមានសំឡេងតិកតុកៗ គ្រប់វិនាទីដែលវាដើរ។ ដូច្នេះហើយទើប ហេនរី សម្រេចចិត្តដកទ្រនិចវិនាទីនោះចេញ។

ប៉ុន្តែទ្រនិចវិនាទីនោះ មានគំនិតមួយផ្សេងទៀត...



ទ្រនិចវិនាទីនោះ បានក្រោកឡើង ហើយបានចាប់ទាញ ហេនរី ចូលទៅក្នុងនាឡិកា។
វឹប!...



នៅពេលដែល ហេនរី បើកភ្នែកឡើង គាត់ក៏បានឃើញខ្លួនរបស់គាត់នៅក្នុងពេលវេលា និងកន្លែងមួយផ្សេងទៀតទ . . . នោះគឺក្នុងប្រទេសអេស៊ីបពីបុរាណកាល...

គាត់បានសួរ ៖ «តើខ្ញុំកំពុងធ្វើអ្វីនៅទីនេះ?»

ទ្រនិចវិនាទីស្រាប់តែលោត តិក តុកៗតប៖ «អ្នកត្រូវរៀនឱ្យតម្លៃខ្ញុំ!.. កាលពីយូរយារណាស់មកហើយ មនុស្សមិនអាចរាប់វិនាទីបានទេ។ នាឡិកាដំបូងបំផុតនោះ គឺនាឡិកាពន្លឺព្រះអាទិត្យ ដែលធ្វើឡើងពីសសរថ្មបួនជ្រុងដូចដែលអ្នកបានឃើញនេះ។ មនុស្សបានវាស់ម៉ោងនិងពេលវេលាតាមរយៈចលនានៃស្រមោលរបស់វានៅលើដី។»



រំពេចនោះ បុរសមួយក្រុមបានដើរសំដៅ និងចោលលំពែង មកកាន់ ហេនរី។ មួយវិនាទី មុនពេលដែលលំពែងនោះហោះ មកចាក់លើខ្លួន ហេនរី ទ្រនិចវិនាទី ក៏ស្រូបទាញ ហេនរី ទៅកាន់ពេលវេលានិងទីកន្លែងមួយផ្សេងទៀត។



ឥឡូវនេះ ពួកគេកំពុងឈរនៅក្នុងបន្ទប់ងងឹតមួយ ដែលបំភ្លឺដោយទៀនមួយដើម។

ទ្រនិចវិនាទី និយាយថា៖ «នេះគឺជាទៀនសម្រាប់កំណត់ពេលវេលា... តើឯងឃើញស្នាមគំនូសនៅលើក្រមួនទៀនដែរឬទេ? ស្នាមគំនូសនីមួយៗនៅលើទៀន នឹងឆេះអស់ក្នុងរយៈពេល ២០ នាទី។»



រំពេចនោះ ផែនដីចាប់ផ្តើមញ័ររញ្ជួយជាខ្លាំង។ហេនរី បានស្រែក ដោយភិតភ័យ៖ «រញ្ជួយផែនដីហើយ។»
ដីចាប់ផ្តើមពុះហែកជាពីរ។ ស្នាមប្រេះកាន់តែធំឡើងៗ និង កាន់តែខិតមកជិតពួកគេទាំងពីរ។ ត្រឹមតែមួយវិនាទីប៉ុណ្ណោះ មុនពេលដែលគេធ្លាក់ចូលទៅក្នុងស្នាមប្រេះនៃផែនដី ទ្រនិច វិនាទី បានចាប់ ហេនរី ហើយពួកគេបានចេញផុតពីទីនោះម្តង ទៀត។




ឥឡូវនេះ ហេនរី កំពុងតែស្ថិតនៅក្នុងកែវស៊ីឡាំងមួយ ជាមួយទ្រនិចវិនាទី។ ពួកគេហាក់ដូចជាមិនបានចាប់អារម្មណ៍ពី ពីស្តុងដែលដើរដោយកម្លាំងទឹក ដែលនឹងកំពុងតែទម្លាក់ខ្លួនមកលើពួកគេឡើយ។

ទ្រនិចវិនាទីបានពន្យល់ថា៖ «□□□□□□□□□□□□□□□ ដែលដំណើរការតាមរយៈការប្រើប្រាស់បារតនិងស្ពឺ។

ហេនរីបាននិយាយថា៖ «គួរឱ្យចាប់អារម្មណ៍ណាស់ ...ប៉ុន្តែ..ប្រយ័ត្ន!..»

ត្រឹមតែមួយវិនាទី មុនពេលដែលពួកគេត្រូវបានកំទេចដោយពី

ស្អុង . . .

វឹប!..



រំពេចនោះ ហេនរី ស្រាប់តែកំពុងដើរលើផ្ទៃរដិបរដុប។ គេមើលទៅក្រោមឃើញស្នឹយក្សពីរកំពុងដើរយឺត ៗ នៅពីក្រោមគាត់។ គេក៏សួរទៅទ្រនិចវិនាទីថា៖ «តើពេលនេះយើងកំពុងនៅកន្លែងណា?»

«យើងកំពុងស្ថិតនៅក្នុង បិក បែន ដែលជាអគារនាឡិកាដ៏ល្បីល្បាញបំផុតនៅលើពិភពលោក។»

ហេនរី បានលោតរំលងលេងយ៉ាងសប្បាយ លើស្នឹរហូតដល់ខ្សែស្បែកជើងរបស់គេជាប់នឹងធ្មេញរបស់ស្នឹ។



ហេនរី បានទាញកន្ត្រាក់ខ្សែស្បែកជើងរបស់គេចេញ ប៉ុន្តែគេមិនអាចយកវាចេញពីស្ពឺនោះបានឡើយ។ ពេលនោះ ប៉ោលដ៏ធំមួយកំពុងតែយោលបោះពួយឆ្ពោះមកកាន់ពួកគេ។

ក្រៅពីសំឡេងតឹកៗរបស់នាឡិកាធំ ទ្រនិចវិនាទីបានស្រែកឡើង៖ «ប្រញាប់ដោះស្បែកជើងឯងចេញទៅ! យើងគ្មានពេលទៀតនោះទេ!..»

ត្រឹមតែមួយវិនាទី មុនពេលដែលប៉ោលនោះយោលមកបុកពួកគេ ទ្រនិចវិនាទី បានទាញ ហេនរី ទៅរកទីដែលមានសុវត្ថិភាព។



ព្រឹកនោះ មានព័ត៌មានមួយនៅលើកញ្ចក់ទូរទស្សន៍ស្តីអំពី បិក បែន ដែលជាប៉មនាឡិកា ដែលជាកន្លែងដែល ហេនរី បាន បាត់ស្បែកជើងរបស់គេ។ ក្នុងរយៈពេល ១៥៨ឆ្នាំនេះ នេះជាលើកដំបូងបង្អស់ដែលប៉មនាឡិកាឈប់វិល។
ហេនរី ស្ទើរតែមិនជឿ។ តើវាជាការពិតដែរទេ? តើស្បែកជើងរបស់គេ ពិតជាកៀបជាប់ក្នុងបិក បែននោះមែនទេ?

មានតែពេលវេលាទេ ដែលអាចបញ្ជាក់បាន . . . ឬ ប្រហែលជាទ្រនិចវិនាទី ទើបអាចដឹង!!



Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Power of Time*, Published by Asafeer, © Asafeer. Released under CC BY-NC-SA 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC-SA 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc-sa/4.0/
Contributing translators: Somey Chheang and Kem Lyheang